## I- ចូរអានប្អូនរឿងខាងក្រោមនេះ

*ព្រះច័ន្ទរបុិលរប៉ូច*

ក្មេងប្រុស និងក្មេងស្រីម្នាក់ កំពុងលេងបាល់ នៅខាងមុខផ្ទះរបស់ពួកគេ ។

តើអ្នកណាគេ ដែលត្រូវវេនបោះបាល់ ?

- វេនខ្ញុំ !
- មិនមែនទេ គឺវេនខ្ញុំទេ !

ការឈ្លោះប្រកែកគ្នាក៏កើតមានឡើង ។ បាល់ព័ណ៌ក្រហម លាយខៀវ ក៏រសាត់ទៅ... វាហោះឡើង ផុតដើមឈើនានា កាន់តែខ្ពស់ទៅៗ ទៅលើមេឃ រហូតដល់ប៉ះនឹងព្រះច័ន្ទ ធ្វើឱ្យព្រះច័ន្ទរបូត ធ្លាក់ចុះមក ! ព្រះច័ន្ទធ្លាក់មកដល់ដី ហើយចាប់ផ្តើមលោតផ្លោតៗ ជាមួយនឹងបាល់ ! គួរឱ្យសប្បាយមែន ឥឡូវនេះមានបាល់ពីរ : បាល់មួយសំរាប់ក្មេងស្រី និងបាល់មួយទៀត សំរាប់ក្មេងប្រុស ។

Procédure = ……………

## II- ចូរប្អូនភ្ជាប់ពាក្យទៅនឹងរូបភាព







| | | |
|---|---|---|
| ផ្ទះ | បាល់ | ក្មេងប្រុស |
| ក្មេងប្រុស | ក្មេងស្រី | ព្រះច័ន្ទ |







…. / 5

## III- ចូរប្អូនគូសរង្វង់ជុំវិញចំលើយ ដែលត្រូវនឹងសំនួរនីមួយៗ



**១ តើក្មេងៗ ធ្វើអ្វី ?**

*ពួកគេច្រៀង ។*

*ពួកគេលេង ។*

*ពួកគេរៀន ។*

**២ ពួកគេលេង នៅឯណា ?**

*នៅក្នុងផ្ទះរបស់ពួកគេ ។*

*នៅក្នុងទីធ្លាសាលារៀន ។*

*នៅមុខផ្ទះពួកគេ ។*

**៣ តើបាល់មានព័ណ៌អ្វីខ្លះ ?**

*ព័ណ៌ក្រហម ។*

*ព័ណ៌ក្រហម លាយខៀវ ។*

*ព័ណ៌ក្រហម លាយស ។*

….. / 3 + ….. / 3 = ….. / 6

**៤ ហេតុអ្វីបានជាមានបាល់ពីរ នៅចុងបញ្ចប់នៃរឿង ?**

*ពីព្រោះក្មេងៗ បានរកឃើញបាល់ទីពីរ នៅក្នុងផ្ទះរបស់ពួកគេ ។*

*ពីព្រោះព្រះអាទិត្យ បានធ្លាក់ពីលើមេឃ ។*

*ពីព្រោះព្រះច័ន្ទ បានធ្លាក់ពីលើមេឃ ។*

**៥ តើរឿងចប់ ដោយរបៀបណា ?**

*ក្មេងៗ ត្រូវគ្នាវិញ ។*

*ក្មេងៗ បន្តឈ្លោះគ្នា តទៅទៀត ។*

*ក្មេងៗ ឈប់លេងបាល់ ។*

**៦ តាមយោបល់ប្អូន តើរឿងនេះ អាចកើតមានមែនទែន ដែរ រឺទេ ?**

*បាទ រឺចាស ។*

*ទេ ។*

*ខ្ញុំមិនដឹងដែរ ។*

….. / 3 + ….. / 3 + ….. / 3 = ….. / 9